ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ 771 PEAC.អក

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការងារម៉ៅការផ្គត់ផ្គង់សម្ភារ និង ឈ្នួលពលកម្មសម្រាប់សាងសង់ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥kV ចំនួន ០១ Circuit ក្នុងចំងាយ ៦.៥ Km ពីអនុស្ថានីយ៍អគ្គិសនីបន្ទាយមាសទៅកាន់រោងចក្រស៊ីម៉ង់ ជីបម៉ុង អ៊ិនស៊ី ស៊ីមិន ខបភើរេសិន

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ៖ អគ្គិសនីកម្ពុជានឹងដាក់ឲ្យដេញថ្លៃជាសាធារណៈដើម្បីការងារម៉ៅការផ្គត់ផ្គង់សម្ភារ និង ឈ្នួលពលកម្មសម្រាប់សាងសង់ខ្សែបញ្ជូនតង់ស្យុងខ្ពស់ 115kV ចំនួន 01 Circuit ក្នុងចំងាយ 6.5km ពីអនុស្ថានីយ៍អគ្គិសនីបន្ទាយមាសទៅកាន់រោងចក្រស៊ីម៉ង់ ជីបម៉ុង អ៊ិនស៊ី ស៊ីមិន ខបភើរេសិន ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ។ ឯកសារដេញថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មដែលមានអាស័យដ្ឋាន៖ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី 22 ខែ មិថុនា ឆ្នាំ2016 តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទំនាក់ទំនងលេខ : 023 67 66 007 និង Website: www.edc.com.kh)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃនៅម៉ោង 14:00 ថ្ងៃទី 26 ខែ កក្កដា ឆ្នាំ 2016។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាស័យដ្ឋានខាងលើវេលាម៉ោង 15:00 ថ្ងៃទី26 ខែ កក្កដា ឆ្នាំ 2016 ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញមកទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ 2016
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ទឹម_អ៊ុំ

**ចម្លងជូន**
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ